# អ្នកនាំសារ
The Messenger

27

ខែកញ្ញា ឆ្នាំ២០០៥- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ




## នៅកូឡូញ
# ការជួបជុំគ្នាជាភាតរភាព



តើថ្នាំដែលគេលក់ទាំងអស់សុទ្ធតែល្អឬ?
ទំព័រ ២



ទស្សនីយភាពសិល្បៈចម្លែកធ្វើពីគ្រឿងអាវុធ
ទំព័រ ៩

ដំណើរឆ្ពោះទៅទីក្រុងកូឡូញរបស់យុវជនខ្មែរ
ទំព័រ ៤

អង្កេត

# តើថ្នាំដែលគេលក់ទាំងអស់សុទ្ធតែល្អ?

**នៅពេលឈឺ គេត្រូវការថ្នាំដើម្បីព្យាបាល ប៉ុន្តែថ្នាំមានច្រើនរាប់រយមុខធ្វើឱ្យលំបាកក្នុងការជ្រើសរើស។ សព្វថ្ងៃនេះ គេឃើញតូប និងផ្ទះលក់ថ្នាំជាច្រើន មាននៅស្ទើរគ្រប់ទីកន្លែងក្នុងទីក្រុងភ្នំពេញ ក៏ដូចជាតាមបណ្តាខេត្តផ្សេងៗក្នុងប្រទេសកម្ពុជា។ តើថ្នាំទាំងនោះមានខ្នាតគំរូ (ស្តង់ដារ) ឬច្បាប់អនុញ្ញាតឱ្យត្រឹមត្រូវដែរឬយ៉ាងណា?**

នាពេលបច្ចុប្បន្ននេះ កម្ពុជា មានរោងចក្រផលិតឱសថប្រហែលជា ៤ ឬ៥ ដែលបានទទួលនូវការអនុញ្ញាតច្បាប់ ពីក្រសួងឧស្សាហកម្ម និងក្រសួងសុខាភិបាល។ ជាមួយនិងដំណើរការផលិត ក៏ដូចជាការលក់ឱសថ ដែលរាជរដ្ឋាភិបាលផ្តល់សិទ្ធិឱ្យ ក៏នៅតែមានជនខិលខូចមួយចំនួនទៀតតែងបានលួចបន្លំលក់ឱសថ ដែលពុំមានគុណភាព (ឱសថក្លែងក្លាយ)នៅតាមឱសថស្ថានខ្លះៗផងដែរ។

### ការចរាចរនៃថ្នាំក្លែងក្លាយនៅលើទីផ្សារ

នៅក្នុងឆ្នាំ២០០០ ក្រសួងសុខាភិបាលបានធ្វើការសិក្សាទូទៅមួយឱ្យដឹងថា ក្នុងចំនួនថ្នាំ ១០០មុខ មានថ្នាំក្លែងក្លាយប្រមាណជាង ១០មុខ។ នៅឆ្នាំ ២០០១ មានឱសថក្លែងក្លាយចំនួន ២៦មុខ ក្នុងចំណោមឱសថប្រមាណ ៣០០មុខ។ ឆ្នាំ២០០២ ឱសថចំនួន ១៣% ជាឱសថក្លែងក្លាយ ដែលលក់នៅភ្នំពេញ និងបណ្តាខេត្តនានា។ នៅឆ្នាំ២០០៣ -២០០៤ មានឱសថក្លែងក្លាយចំនួន ៣៥មុខ លើឱសថ ៣៣០មុខ។ ការសិក្សាមួយ នាឆ្នាំ២០០៤ បានបង្ហាញថា មាន ៣៥% គឺជាឱសថ ដែលមានការសង្ស័យ។ ក្នុងការសិក្សាមួយទៀតបានឱ្យដឹងថា មានកន្លែងលក់ឱសថ ៩០០កន្លែង មានច្បាប់ និងជាង ៨០០កន្លែង គ្មានច្បាប់។ មកដល់ពេលនេះឱសថដែលចុះបញ្ជីការមានប្រហែល ៦០០០ មុខ ហើយឱសថមិនចុះបញ្ជីការ មាន ៥០%។

ទាក់ទងទៅនឹងបញ្ហានេះ លោករ៉េង ថៃ ប្រធានមន្ទីរសុខាភិបាលរាជធានីបានពោលថា: "បើតាមស្ថិតិចុងក្រោយ នៅខណ្ឌ៩ ក្នុងចំណោមខណ្ឌទាំង ៧ កន្លែងលក់ឱសថឥតច្បាប់ស្រង់បាន មានចំនួន ៩២កន្លែង។ ផ្ទះលក់ឱសថទ្រង់ទ្រាយល្មម (លក់តែឱសថ)មាន ៥% ផ្ទះលក់ឱសថដែលមានការពិគ្រោះជំងឺមាន ៩០% និងផ្ទះលក់ឱសថតូចតាចមាន ៥%។ លោកបន្ថែមទៀតថា ទីក្រុងភ្នំពេញធ្លាប់បានបើកយុទ្ធនាការធំៗ ដើម្បីបំបាត់ការលក់ឱសថឥតច្បាប់ដែរ ប៉ុន្តែលទ្ធផលនៅមិនទាន់បានល្អដោយបរិបទនយោបាយ និងសង្គម។

តាមការសិក្សារបស់អង្គការសុខភាពពិភពលោកបានឱ្យដឹងថា ពលរដ្ឋក្រីក្រគឺជាអ្នកដែលប្រឈមមុខទៅនឹងថ្នាំក្លែងក្លាយច្រើនជាងគេ ដោយសារឱសថទាំងនោះមានតម្លៃថោក។

### ផលប៉ះពាល់ និងការទប់ស្កាត់ថ្នាំក្លែងក្លាយ

លោកកែវ ស៊ុន ណារី ដែលជាឱសថការីឧត្តមនៅខេត្តកំពង់ស្ពឺបាននិយាយថា ឱសថក្លែងក្លាយគឺជាឱសថ ដែលកម្រិតគុណភាពរបស់វា មិនបានគ្រប់ទៅតាមកម្រិតស្តង់ដារ ដែលនាំដល់ការព្យាបាលមិនមានប្រសិទ្ធភាព។ លោកយឹម យ៉ាន់ ដែលជាប្រធានការិយាល័យឱសថ រាជធានីភ្នំពេញ ក៏បានមានប្រសាសន៍ថា: "ទោះបីជាគេគឺជាវេជ្ជបណ្ឌិតឬជាឱសថការីក៏ដោយ គេនៅតែមានការលំបាកក្នុងការចំណាំដែរ ព្រោះប្រភេទថ្នាំល្អ និងថ្នាំក្លែងក្លាយមើលពីក្រៅទៅ គឺដូចគ្នា ហើយម្យ៉ាងទៀតថ្នាំក្លែងក្លាយ វាមានតម្លៃថោក និងច្រើននាំចេញទៅលក់នៅតាមបណ្តាខេត្តឆ្ងាយៗ ព្រោះប្រជាពលរដ្ឋក្រីក្រនៅតាមជនបទមិនសូវយល់ដឹងពីគុណភាពឱសថច្បាស់លាស់នៅឡើយទេ។

កញ្ញាគឹម ផល្លា ដែលជាបុគ្គលិកនៃអង្គការ JRS បាននិយាយថា នាងតែងទៅជួបជាមួយគ្រូពេទ្យជាមុនដើម្បីពិគ្រោះយោបល់ មុននឹងសុំវេជ្ជបញ្ជាដើម្បីទិញថ្នាំ។ នាងបានបន្ថែមថា យើងមិនអាចដឹងបានទេថា ថ្នាំណាមួយជាថ្នាំពិត ឬក្លែងក្លាយនោះ ដូច្នេះសំខាន់អ្នកជំងឺត្រូវតែមានវេជ្ជបញ្ជាពីពេទ្យជាមុនសិន។ ក្នុងគំនិតដូចគ្នានេះ កញ្ញាធីតា បានឱ្យដឹងថា វាពុំមែនជាប្រការល្អទេ ដែលយើងទៅទិញថ្នាំនៅតាមឱសថស្ថាននានា ដោយពុំមានវេជ្ជបញ្ជានោះ ប៉ុន្តែយើងអាចទៅរកទិញថ្នាំបាននៅតាមឱសថស្ថានណា ដែលយើងជឿទុកចិត្តថាជាកន្លែងលក់ស្របច្បាប់។ បញ្ហាដែលកញ្ញាព្រួយបារម្ភមួយទៀត គឺនៅតាមឱសថស្ថាន មួយចំនួនអ្នកលក់ពុំមានវិជ្ជាជីវៈពេទ្យ ឬឯកទេសនៅខាងផ្នែកឱសថទាល់តែសោះ។

ចំណែកលោកហេង ហួត ដែលជាប្រធានការិយាល័យនិយ័តកម្មនៃនាយកដ្ឋានឱសថ បាននិយាយឡើងថា ការបិទលតប័ត្រ (ច្បាប់អនុញ្ញាតចេញពីក្រសួងសុខាភិបាល) លើប្រអប់ឱសថ គឺវាមានសារៈសំខាន់ណាស់ ក្នុងការបែងចែក រវាងឱសថរត់ពន្ធ (ក្លែងក្លាយ) និងឱសថដែលស្របច្បាប់។ លោកបន្ថែមថា សម្រាប់សារាចរណ៍នេះ ក្រសួងបានធ្វើការណែនាំ និងផ្សព្វផ្សាយដល់គ្រប់ក្រុមហ៊ុនឱសថតាំងតែពីដើមឆ្នាំ២០០៥មក។ ក្រសួងទុកពេល ៦ខែ ឱ្យក្រុមហ៊ុនធ្វើការងារនេះ។

នាថ្ងៃទី០១ តុលា ឆ្នាំ២០០៥ខាងមុខនេះ ក្រសួងនឹងចុះត្រួតពិនិត្យនៅតាមបណ្តាក្រុមហ៊ុនឱសថនានា ថាតើគេមានអនុវត្តន៍ តាមការណែនាំរបស់ក្រសួងឬទេ?។ បន្ទាប់មកក្រសួងក៏នឹងចុះពិនិត្យតាមឱសថស្ថានរងនៅភ្នំពេញ និងនៅតាមបណ្តាខេត្តក្រុងដែរ។ វិធានការនេះ អាចនឹងជោគជ័យបាន លុះត្រាតែមានការជួយគាំទ្រពីសំណាក់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋដែលភ្ញាក់រឭក ព្រមទាំងមនសិការវិជ្ជាជីវៈនៃអាជីវករ និងក្រុមហ៊ុនផងដែរ។ ម្ចាស់ឱសថស្ថាន១រូប បាននិយាយថា: "ដើម្បីបំបាត់ឱសថក្លែងក្លាយ ត្រូវតែបំបាត់អំពើពុករលួយតាមច្រកនាំចូលឱ្យអស់ជាមុនសិន"។

អង្កេតដោយ: មុំ គន្ធា



Photos: M. Kunthear

សម្រាប់ថ្នាំទាំងនេះយើងមិនដឹងថាពួកវាល្អឬក្លែងក្លាយទេ

### ប្រទេសនាំឱសថចូល

សព្វថ្ងៃមានការនាំចូលឱសថពីប្រទេសៈ បារាំង ថៃ ឥណ្ឌា ម៉ាឡេស៊ី អូស្ត្រាលី កូរ៉េ ហុងកុង អាឡឺម៉ង់ និងប្រទេសផ្សេងៗ ដទៃទៀត។ ការចុះបញ្ជីការឱសថគឺជាការយកឯកសារ លិខិត ដែលទាក់ទងនឹងឱសថឱ្យក្រសួងសុខាភិបាលត្រួតពិនិត្យ។ ឱសថត្រូវចុះទិដ្ឋាការ ដែលជាការចុះត្រួតពិនិត្យមើលឱ្យបានត្រឹមត្រូវមុននឹងឱ្យដាក់លក់នៅលើទីផ្សារក្នុងប្រទេសកម្ពុជា។



# វិធានការលុបបំបាត់ឱសថក្លែងក្លាយនៅលើទីផ្សារ

**ច្បាប់ចែងថា អ្នកលក់ថ្នាំខុសច្បាប់ត្រូវជាប់គុកពី៥-១០ឆ្នាំ ពិន័យប្រាក់ពី២០-៥០លានរៀល ហើយជនចែកចាយថ្នាំគ្មានតែមចុះបញ្ជីការអាចនឹងត្រូវផាកពិន័យពី១ទៅ១០លានរៀល។**

យុទ្ធសាស្ត្រ សម្រាប់ឆ្នាំ២០០៣ ដល់២០០៧ របស់ក្រសួងសុខាភិបាលក្នុងការលុបបំបាត់ថ្នាំក្លែងក្លាយ មានវិធានការបីធំៗ គួរឱ្យយកចិត្តទុកដាក់ និងអនុវត្តដែលក្នុងនោះរួមមានៈ

ទី១ បោសសំអាតកន្លែងលក់ឱសថអត់ច្បាប់តាមគ្រប់វិធីរដ្ឋបាល ដូចជាណែនាំអប់រំ ប្រើច្បាប់តុលាការ និងសិទ្ធិរបស់ភ្នាក់ងារឱសថ។

ទី២ សំណូមពរដល់ក្រសួងសុខាភិបាលរៀបចំគ្រប់គ្រងឱ្យបានឆាប់ចំពោះយន្តការ ឬប្រព័ន្ធចែកចាយឱសថ ដែលធានាគុណភាព ជាមួយការទទួលខុសត្រូវ ត្រួតពិនិត្យតាមដានដោយមានល័ក្ខខ័ណ្ឌតាំងពីដើមទីរហូតចុងទីអំពីការផលិត ការនាំចូល ការស្តុកទុក រហូតដល់ការបែងចែក ផ្តល់ព័ត៌មានអំពីការដឹកជញ្ជូន ការផ្សព្វផ្សាយផលិតផល និងប្រភេទឱសថ ទាក់ទងនឹងវេជ្ជបញ្ជា ប្រភេទសេវា និងព្រមទាំងបណ្តាក្បួនខ្នាតផ្សេងៗជាច្រើនទៀត។ ពេលដែលកិច្ចការទាំងនេះត្រូវបានរៀបចំរួចរាល់ និងមានដំណើរការល្អហើយនោះ វានឹងធ្វើឱ្យក្រុមអ្នកលក់ឱសថអត់ច្បាប់ នឹងត្រូវគេ"ផ្តាច់ជីវិត" យ៉ាងឆាប់នៅពេលនោះដែរ។

ទី៣ ធានា និងលើកកម្ពស់សីលធម៌មនសិការវិជ្ជាជីវៈ គោរពសិទ្ធិមនុស្ស និងជីវិតមនុស្សនៅក្នុងបេសកកម្មនៃការប្រកបវិជ្ជាជីវៈ។

ចរិតអវិជ្ជមាន នៃកត្តាទាំងបីខាងលើនេះ ជាមូលដ្ឋាន នៃអ្វីដែលហៅថា "អនាធិបតេយ្យ" របស់អាជីវករអ្នកលក់ឱសថ។

អនុលោមទៅតាមអនុក្រឹត្យ លេខ៤៤ អនក្រ ចុះថ្ងៃទី១០ សីហា ឆ្នាំ១៩៩៤ ស្តីអំពីទិដ្ឋាការបញ្ជីការឱសថរបស់រាជរដ្ឋាភិបាល ដើម្បីបែងចែកលក្ខណៈខុសគ្នា រវាងឱសថ ដែលបានចុះបញ្ជីការ និងឱសថដែលមិនបានចុះបញ្ជីការពីក្រសួងសុខាភិបាល ជាពិសេស គឺភាពខុសគ្នារវាងឱសថដែលមានការត្រួតពិនិត្យគុណភាពមិនច្បាស់លាស់នោះ ក្រសួងសុខាភិបាលមានវិធានការដូចតទៅ គ្រឹះស្ថានអាហរ័ណ នីហ-រ័ណទាំងអស់ត្រូវបិទលតប័ត្រនៅលើប្រអប់ឱសថគ្រប់ប្រភេទ ដែលបាននាំចូល សម្រាប់លក់ចែកចាយទៅឱ្យដល់គ្រប់ឱសថស្ថាន និងឱសថស្ថានរងស្របច្បាប់នៅទូទាំងប្រទេស។ លតប័ត្រមានផ្ទៃពណ៌ស ហើយក៏មានបញ្ជាក់ឈ្មោះគ្រឹះស្ថាន អាហរ័ណនីហរ័ណឱសថ និងលេខបញ្ជីការឯកភាពពីក្រសួងសុខាភិបាល។ លតប័ត្រនីមួយៗ ត្រូវមានសរសេរឈ្មោះគ្រឹះស្ថាន អាហរ័ណនីហរ័ណឱសថ និងលេខបញ្ជីការ។ លតប័ត្រត្រូវតែបិទឱ្យបានជាប់នៅលើប្រអប់ឱសថដោយទទួលយល់ព្រមពីនាយកដ្ឋានឱសថផងដែរ។ ឱសថដែលអាចដាក់លក់លើទីផ្សារបាន លុះត្រាតែបានឆ្លងកាត់ការចុះបញ្ជីការ និងត្រូវមានចុះទិដ្ឋាការត្រួតពិនិត្យមើលឱ្យបានត្រឹមត្រូវផងដែរ។




ផ្លាកសញ្ញាសម្គាល់ថាឱសថស្ថានមានលក្ខណៈស្របច្បាប់

ROME





រូបលើៈ ពិធីអភិបូជាដែលប្រារព្ធឡើងនៅកន្លែងសន្តប៉ូល។
រូបក្រោមៈ ការទទួលទានអាហារជួបជុំគ្នារវាងក្រុមយុវជននៅក្នុងភោជនីយដ្ឋានមួយនាទីក្រុងរ៉ូម។







រូបលើៈ ក្រុមយុវជនកាតូលិកខ្មែរ នៅពេលបានទៅដល់ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី។
រូបស្តាំៈ ថតរូបជុំគ្នាបួននាក់រួមជាមួយនិងអាណិកជនខ្មែរនៅទីក្រុងរ៉ូមដដែល។
រូបខ្ពស់វែងខាងក្រោមៈ ការឡើងបង្ហាញខ្លួននៃក្រុមយុវជនក្នុងពិធីអភិបូជានៅទីក្រុងរ៉ូសេតូ។
រូបតូចខាងក្រោមៈ ពិធីទទួលព្រះកាយ។





**ជី ស៊ុនសុធារីៈ** “ទោះបីជាខ្ញុំមិនទាន់បានក្លាយជាគ្រិស្តបរិស័ទពេញលេញក៏ដោយ តែនៅពេលដែលខ្ញុំបានទៅដល់ប្រទេសអាឡឺម៉ង់ ខ្ញុំចាប់អារម្មណ៍ទៅលើពួកគេ ដោយសារការចេះជួយគ្នាជាក្រុម និងចេះសាមគ្គីគ្នា។ នេះគឺជាបទពិសោធន៍មួយដ៏ល្អសម្រាប់ខ្ញុំ។ ខ្ញុំនឹងបង្កើតជាក្រុមការងារយុវជនដើម្បីធ្វើការអភិវឌ្ឍន៍ប្រទេសជាតិ ក៏ដូចជាព្រះសហគមន៍របស់យើងដែរ”។



រូបទាំងបីខាងលើរាប់ពីឆ្វេងៈ ទី១ ក្រុមយុវជនថតរូបអនុស្សាវរីយ៍នៅពីមុខប្រាសាទចាស់នាទីក្រុងរ៉ូមដែលជាកន្លែងដែលគេធ្លាប់សម្លាប់គ្រិស្តបរិស័ទកាលពីជំនាន់ដើម។ ទី២ លោកឪពុកហ្វ្រាន់កូរ សម្រាកញ៉ាំអាហារសម្រន់ក្រពះ។ ទី៣ ថតរូបជុំគ្នានៅឯអាកាសយានដ្ឋានទីក្រុងរ៉ូម។
រូបខាងស្តាំៈ រូបគំនូរដ៏ចំណាស់មួយនៅក្នុងវិសាលវិហារទីក្រុងរ៉ូម។

# កម្រងរូបថតយុវជនខ្មែរ

**ឆាន ស្រីអែមៈ** “ខ្ញុំមានអំណរសប្បាយដោយបានឃើញព្រះភ័ក្រ្តសម្តេចប៉ាប។ ខ្ញុំបានចាប់អារម្មណ៍ចំពោះយុវជនទាំងអស់គ្រប់ជាតិសាសន៍ ទោះបីជាយើងមានភាសាខុសគ្នាក្តី ប៉ុន្តែកាយវិការរបស់យើងបង្ហាញពីសេចក្តីស្រលាញ់មួយដ៏ជ្រាលជ្រៅ”។







រូបពីរតូចខាងលើៈ ការចូលរួមរាំកំសាន្តនៅក្នុងពិធីជប់លៀងមួយនៅទីក្រុងរ៉ូសេតូដែលជាក្រុងកំណើតរបស់លោកឪពុកអេរីកូ។
រូបក្រោមៈ ទិដ្ឋភាពឆ្នេរសមុទ្រនៅឯទីក្រុងរ៉ូសេតូ។

ROSETO





រូបធំនេះៈ ទិដ្ឋភាពថតពីលើអាកាសនៃទីក្រុងអាស៊ីសស៊ី។
រូបតូចពីរខាងស្តាំបង្អស់ៈ រូបលើស្តាំ ព្រះវិហារមួយនៅអាស៊ីសស៊ី។ រូបក្រោមៈ ដូនជីសម្ងាត់ម្នាក់នៃសន្តីក្លារ៉ា។

ASSISI







នៅមានតលេខក្រោយ!

# គោលដៅចម្បងក្នុងការប្រយុទ្ធប្រឆាំងអនក្ខរកម្ម



Photo: SOMNE THEY

ការបង្រៀនក្មេងៗពុំចេះអក្សរនៅភូមិជនបទមួយ

ទិវាអនក្ខរកម្ម ៨ កញ្ញា បានរៀបចំនៅសួនច្បារសម្ដេចហ៊ុន សែន ក្រោមអធិបតីភាពសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន។ នាឱកាសនោះលោកកុល ផេង រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាបានវាយតម្លៃថា ក្នុងចំណោមប្រជាជនសរុបប្រមាណ ១៣លាននាក់ មានអត្រាអនក្ខរជនចំនួន ៣០%។ លោកបន្តថា: "រយៈពេលមួយឆ្នាំសោះមានចំនួនសិស្សរៀនអក្ខរកម្មកើនឡើងពី ៩០០៤៥នាក់ ទៅដល់ ១០៥៤៣០នាក់ ដែលក្នុងចំណោមនោះ សិស្សភាគច្រើនគឺជាស្ត្រី"។ ក្នុងនោះដែរសម្ដេចនាយករដ្ឋមន្ត្រីក៏បានប្រគល់រង្វាន់ដល់សិស្សពូកែ ១០នាក់ ដែលជាអតីតសិស្សអនក្ខរកម្ម ហើយសម្ដេចក៏បានសុំឱ្យកុមារ ដែលមានអាយុច្រើន ឬកុមារដែលបានបោះបង់ចោលការសិក្សា ត្រូវបានសាលារដ្ឋទទួលឱ្យចូលរៀនវិញដោយគ្មានផលលំបាក ហើយសម្ដេចបានធ្វើការអំពាវនាវឱ្យអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការលើផ្នែកនេះឱ្យពង្រឹងសកម្មភាពរបស់ពួកគេ។

សំណេរថ្មី

## អង្គការថ្មីជួយរកការងារឱ្យនិស្សិត

អង្គការ "យុវតារា" ត្រូវបានផ្ដួចផ្ដើមគំនិតបង្កើតឡើងដោយលោកស្រីអេវ៉ាមីស្លីវី ដែលជាប្រធានវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍។ អង្គការ មានគោលដៅជំរុញឱ្យយុវជនឱ្យចូលរួមកសាងជាតិដោយសន្តិសុខ និងយុត្តិធម៌ ដោយជួយបញ្ចូលពួកគេទៅក្នុងទីផ្សារការងារ។ លោកស្រីនាយិកាអង្គការថ្មីនេះ ក៏បាននិយាយថា គ្រប់យ៉ាងត្រូវបានចាប់ផ្ដើមក្រោយពីបានសង្កេតឃើញថា មានតែយុវជន ដែលទើបតែបញ្ចប់ការសិក្សា ១ភាគ៩ប៉ុណ្ណោះ ដែលអាចរកការងារបានខណៈពេល ដែលប្រទេសកម្ពុជាមាននិស្សិតរហូតទៅដល់ ៩១៣០៩នាក់។ អង្គការនឹងជ្រើសរើសយុវជនស្ម័គ្រចិត្ត ដែលទើបបញ្ចប់ការសិក្សាចំនួន ៨០នាក់ ឱ្យធ្វើការងារជាមួយនិងកិច្ចសន្យារយៈពេលមួយឆ្នាំ។ ពួកគេនឹងត្រូវបញ្ជូនទៅកាន់ខេត្តកំពង់ចាម ព្រៃវែង និងស្វាយរៀង ដើម្បីធ្វើការក្នុងសហគមន៍ជាថ្នូរនឹងប្រាក់ខែ ៩០ដុល្លារ ដោយថែមថ្លៃស្នាក់នៅផង។ យុវជនទាំងនេះនឹងទទួលការបណ្ដុះបណ្ដាលនៅភ្នំពេញរៀងរាល់ ៣ខែម្ដង និងត្រូវធ្វើរបាយការណ៍អំពីសកម្មភាពពួកគេ។ យុវជនពុំអាចធ្វើការហួសពី១ឆ្នាំទេ ប៉ុន្តែអង្គការសន្យាថា អ្នកដែលត្រូវបានជ្រើសរើស ក៏នឹងអាចដាក់ពាក្យសុំធ្វើការនៅក្រុមហ៊ុនឯកជនបាន។

កំបូជស័រ

## សារមន្ទីរភូមិបុរាណខ្មែរ ខេត្តសៀមរាប

សារមន្ទីរភូមិបុរាណខ្មែរទើបតែត្រូវបានបើកទ្វារឱ្យភ្ញៀវទេសចរចូលទស្សនាក្នុងភូមិព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ នៅក្នុងនោះគេឃើញមានសុទ្ធតែឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនខ្មែរដូចជា រទេះគោ កណ្ដៀវ ទូក-ល-។ សារមន្ទីរនេះមានសណ្ឋានជារោងឈើប្រក់ស្លឹកត្នោត ចំនួន៤ និងផ្ទះប្រក់ស្លឹកត្នោតចំនួនពីរ។ លោកតែ អៃលី ម្ចាស់កន្លែងអះអាងថា ការធ្វើនេះគឺដើម្បីលើកស្ទួយទេសចរណ៍ និងបង្ហាញអំពីកេរមរតកខ្មែរ។

សំណេរថ្មី

## អន្តរជាតិ

### លោកកូអ៊ីហ្សូមីទទួលជោគជ័យសាជាថ្មី

នៅប្រទេសជប៉ុន គណបក្សនៃលោកនាយករដ្ឋមន្ត្រីហ្សូនីឈីរ៉ូ កូអ៊ីហ្សូមី ទទួលជ័យជម្នះក្នុងការបោះឆ្នោតដោយសំលេងភាគច្រើនលើសលប់។

បន្ទាប់ពីរង់ចាំទទួលលទ្ធផលរយៈពេលជាងមួយសប្ដាហ៍មក នៅថ្ងៃទី១១ ខែកញ្ញា ប្រទេសជប៉ុនក៏ដូចប្រទេសដទៃមានការភ្ញាក់ផ្អើល ដោយសារតែលោកនាយករដ្ឋមន្ត្រី កូអ៊ីហ្សូមី ដែលជាប្រធានគណបក្សប្រជាធិបតេយ្យសេរីទទួលសំលេងឆ្នោតបានយ៉ាងច្រើនលើសលប់។ គណបក្សប្រជាធិបតេយ្យសេរីគឺជាគណបក្សមួយក្នុងចំណោមគណបក្សចំនួនពីរ ដែលឈរឈ្មោះ បានទទួលកៅអី២៩៦ក្នុងចំណោមកៅអី៤៨០។ វាគឺជាលើកទីមួយក្នុងរយៈពេល ១៥ឆ្នាំ ដែលគណបក្សនេះបានទទួលសំលេងឆ្នោតលើសជាងពាក់កណ្ដាលក្នុងចំណោមសំលេងសរុប។ លោកនាយករដ្ឋមន្ត្រីជប៉ុន បាននិយាយថា: "ខ្ញុំត្រូវបានគាំទ្រពីប្រែសនីយ៍ជាច្រើនឆ្នាំមកហើយ។ សភាបាននិយាយថា វាពុំមានហេតុផលអ្វីដែលត្រូវឈ្លោះប្រកែកគ្នានោះទេ"។ លោកមានប្រសាសន៍បន្ថែមទៀតថា: "ខ្ញុំមិនមានបំណងនៅឈរជាប្រធានគណបក្ស និងនាយករដ្ឋមន្ត្រីទៀតទេចាប់ពីខែកញ្ញា ឆ្នាំ២០០៦ ខាងមុខនេះតទៅ"។

មុំ គន្ធា





# យើងនាំគ្នាថ្វាយបង្គំព្រះយេស៊ូគ្រិស្ដ

យុវជន-នារីប្រមាណជា ៤០០នាក់នៃភូមិភាគបាត់ដំបង ភ្នំពេញ និងកំពង់ចាមបានមកជួបជុំគ្នាចាប់ពីថ្ងៃទី២៩ សីហា ដល់ថ្ងៃ០២ កញ្ញា នៅព្រះសហគមន៍បាត់ដំបងដើម្បីរិះគិតលើប្រធានបទ "យើងនាំគ្នាថ្វាយបង្គំព្រះយេស៊ូគ្រិស្ដ"។



Photo: L. Sovanna

យុវជនរួមគ្នារិះគិតអំពីរបៀបនៃការធ្វើជាសាក្សីរបស់ព្រះយេស៊ូគ្រិស្ដនៅក្នុងសង្គម

យោងតាមលិខិតស្នើសុំរបស់សម្ដេចប៉ាបយ៉ូហាន ប៉ូល ទី២ ដោយបានសុំឱ្យព្រះសហគមន៍ក្នុងពិភពលោក ទទួលយកឆ្នាំ ២០០៥ គឺជា "ឆ្នាំគោរពព្រះកាយព្រះគ្រិស្ដ" ព្រះសហគមន៍កម្ពុជាបានខិតខំទទួល និងអនុវត្តយ៉ាងខ្ជាប់ខ្ជួន ដោយមានធ្វើពិធីអធិដ្ឋានគោរពព្រះកាយ (តាំងព្រះកាយ) រៀងរាល់សប្ដាហ៍នៅក្នុងព្រះសហគមន៍នីមួយៗ។ លើសពីនេះ ក៏មានការរៀបចំនូវអង្គសន្និបាតព្រះសហគមន៍ប្រចាំនៅភូមិភាគនីមួយៗ ដើម្បីរិះគិតឱ្យបានស៊ីជម្រៅនូវរបៀបគោរព កាយវិការ និងជាពិសេសអំពីអត្ថន័យរបស់ "អគ្គសញ្ញាព្រះកាយ និងព្រះលោហិតនៃព្រះយេស៊ូគ្រិស្ដ"។ សម្រាប់នៅភូមិភាគបាត់ដំបង គេនៅបន្តផ្ដល់ការរិះគិតនេះដល់យុវជន យុវនារីរបស់ខ្លួន ដោយបានលើកយកប្រធានបទ "យើងនាំគ្នាថ្វាយបង្គំព្រះយេស៊ូគ្រិស្ដ" នៅក្នុងអង្គសន្និបាតយុវជន-នារី លើកទី៥នេះ ដែលជាប្រធានបទដូចគ្នានឹងប្រធានបទនៅក្នុងទិវាយុវជនពិភពលោកនៅប្រទេសអាឡឺម៉ង់ដែរ។

លោកបូជាចារ្យប៉េដ្រូ ដែលជាអ្នកទទួលខុសត្រូវនៅក្នុងការរៀបចំសន្និបាត លើកទី៥នេះ បានគូសបញ្ជាក់ថា ការបន្តឱ្យយុវជនយល់អំពីអត្ថន័យនៃការថ្វាយបង្គំ (អភិបូជា) វាគឺជាការសំខាន់ណាស់ ដើម្បីឱ្យស្គាល់អំពីរបៀបនៃការថ្វាយបង្គំ "ឱ្យត្រូវទៅនឹងជំនឿ និងឱ្យត្រូវទៅតាមព្រះបន្ទូល"។ ការថ្វាយបង្គំឱ្យត្រូវនឹងជំនឿ និងព្រះបន្ទូល លោកបូជាចារ្យរូបនេះក៏បានបញ្ជាក់ថា: "គឺការថ្វាយនូវអ្វីដែលសំខាន់មានក្នុងដួងចិត្តរបស់យើងទៅព្រះជាម្ចាស់ នៅពេលយើងថ្វាយបង្គំ ហើយកាយវិការត្រូវឱ្យសមទៅតាមប្រពៃណីខ្មែរ និងប្រពៃណីរបស់ព្រះសហគមន៍ ប៉ុន្តែយើងត្រូវយល់នូវកាយវិការនីមួយៗឱ្យបានច្បាស់លាស់"។ យុវជនកាន់ ប៊ុយ ដែលមកពីព្រះសហគមន៍ខ្នាចរមាស បានយល់ស្របនឹងអ្វីដែលលោកបូជាចារ្យប៉េដ្រូមានប្រសាសន៍ និងបានបង្ហាញពីបទពិសោធន៍របស់ខ្លួនថា នៅពេលអភិបូជា តាមរយៈកាយវិការដែលយើងគោរពព្រះជាម្ចាស់ ធ្វើឱ្យលោកយល់ និងចេះបង្កើតនូវទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងអ្នកដទៃ ហើយក៏ធ្វើឱ្យលោកយល់អំពីជីវិតខ្លួនដែលត្រូវពឹងផ្អែកលើការលើកលែងទោសរបស់ព្រះជាម្ចាស់ជានិច្ច។ ដោយសារខ្លួនពុំទាន់ទទួលព្រះកាយ យុវជនរូបនេះបន្តថា: "ព្រះជាម្ចាស់ គឺគង់នៅជាមួយខ្ញុំតាមរយៈព្រះបន្ទូល ហើយព្រះបន្ទូលធ្វើឱ្យខ្ញុំទទួលនូវអត្ថន័យថ្មីសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃផងដែរ"។

រីឯយុវជន ភឹង សម្បត្តិ ដែលមកពីព្រះសហគមន៍ចំណោមក៏បានបញ្ជាក់ថា "ព្រះអម្ចាស់តែងគង់នៅជាមួយខ្ញុំពេលដែលខ្ញុំទទួលព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រិស្ដ"។ យុវជនរូបនេះបន្តថា វត្តមានរបស់ព្រះជាអម្ចាស់ គឺនៅត្រង់ពិធីកាច់នំប៉័ង ដែលព្រះយេស៊ូបានប្រទាននូវព្រះកាយរបស់ព្រះអង្គផ្ទាល់។ នៅក្នុងអភិបូជា លោកបានត្រងត្រាប់ស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយក៏យកទៅអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃនៅក្នុងសង្គម។ យើងអាចធ្វើជាសាក្សីព្រះជាម្ចាស់នៅទីកន្លែងដែលយើងរស់នៅ។ "អភិបូជាត្រូវតែបន្តរហូត" ដែលពុំមែនមានតែក្នុងព្រះវិហារទេ។ យើងត្រូវធ្វើជាសាក្សីរបស់ព្រះអម្ចាស់គ្រប់ពេលវេលា និងគ្រប់កាលៈទេសៈក្នុងដំណើរជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។

លី សុវណ្ណា

### អំពីអភិបូជា

ការថ្វាយបង្គំ (អភិបូជា) គឺជាសេចក្ដីសង្ខេបនៃជំនឿក្នុងដំណាក់ការនៃជីវិតប្រចាំថ្ងៃរបស់យើង។ ដោយសារនាក្នុងអភិបូជា យើងថ្វាយកាយវាចា និងចិត្តចូលរួមក្នុងពិធីកាច់នំប៉័ង (ជប់លៀង) ជាមួយនិងព្រះអម្ចាស់។ វាមានបីដំណាក់កាលគឺ ពិធីប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ និងពិធីចាត់ឱ្យទៅដោយទទួលកម្លាំងពីព្រះជាម្ចាស់ និងព្រះវិញ្ញាណដើម្បីបន្តរស់នៅធ្វើជាសាក្សីនៃសេចក្ដីស្រលាញ់របស់ព្រះគ្រិស្ដក្នុងដំណើរជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។

# ដល់ពេលនារីៗលេងបាល់ទាត់

**កន្លងមកគេធ្លាប់ឃើញតែបុរសៗ លេងបាល់ទាត់ ដែលជាកីឡាដ៏ពេញនិយម។ ប៉ុន្តែនៅពេលនេះ ពន្លកនៃកីឡាការិនីបាល់ទាត់ក្មេងៗកំពុងចាប់ផ្តើមដុះដាលហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។**



កីឡាការិនីវ័យក្មេងៗកំពុងតែលេងបាល់ទាត់ដោយទទួលការបង្វឹកតាមក្បួនខ្នាតច្បាស់លាស់

Photo: P. Samphy

ក្រុមកីឡាបាល់ទាត់នារីៗនៃរាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងអំឡុងពាក់កណ្តាលខែកក្កដា ឆ្នាំ២០០៥កន្លង ទៅនេះ ក្រោមការផ្តួចផ្តើមគំនិតរបស់លោកស្រីអ៊ុត ច័ន្ទបូរ ដែលជាប្រធានការិយាល័យកីឡា រាជធានីភ្នំពេញ និងមានការចូលរួមពីយុវនារីក្មេងៗ ដែលមានអាយុពី១៥ ដល់២៥ឆ្នាំ។ យុវនារីទាំងនេះ មានភាគច្រើនជាយុវសិស្សនៅតាមវិទ្យាល័យ និងខ្លះទៀតជាគ្រូអប់រំកាយ និងកីឡា ព្រមទាំងមហាជនទូទៅផងដែរ។ ក្នុងមួយសប្តាហ៍ ពួកគេធ្វើការហ្វឹកហាត់ប្រាំថ្ងៃ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ នៅតាមកន្លែងទីទៃពីគ្នា គឺថ្ងៃខ្លះនៅវិទ្យាល័យឥន្ទ្រទេវី ជួនកាលនៅវិទ្យាល័យបាក់ទូក និងថ្ងៃខ្លះទៀតនៅពហុកីឡាដ្ឋានជាតិអូឡាំពិក។

តាមប្រសាសន៍លោកស្រីអ៊ុត ច័ន្ទបូរបានឱ្យដឹងថា ហេតុផលដែលធ្វើឱ្យលោកស្រីបង្កើតកីឡាបាល់ទាត់នារីនេះឡើង គឺដោយសារវិញ្ញាសាកីឡាបាល់ទាត់នារីនេះ ពុំទាន់ឃើញមាននៅក្នុងប្រទេសកម្ពុជាយើង ក្នុងខណៈដែលប្រទេសជិតខាងមានក្រុមបាល់ទាត់នារីអស់ហើយនោះ។ ម្យ៉ាងទៀត យើងចង់បង្ហាញផងដែរថា បើក្រុមបុរសគេអាចធ្វើនូវរឿងអ្វីបាន នារីក៏មានសមត្ថភាពអាចធ្វើវាបានដែរ។

ជាក់ស្តែង លោកច័ន្ទ សុទ្ធ ដែលជាគ្រូបង្វឹកម្នាក់ឱ្យក្រុមបាល់ទាត់នារីទាំងនេះបាននិយាយថា: "បច្ចេកទេសនៃការប្រកួតបាល់ទាត់នារី គឺមានលក្ខណៈដូចគ្នាទៅនឹងបាល់ទាត់បុរសដែរ ទាំងចំនួនមនុស្ស (មាន១១នាក់សម្រាប់មួយក្រុមក្នុងមួយពេលប្រកួត) រយៈពេលប្រកួត និងទាំងទំហំទីលាន"។ ប៉ុន្តែទោះជាយ៉ាងនេះក្តី លោកឃួន ណារិទ្ធ ដែលជាគ្រូបង្វឹកម្នាក់ទៀតបានបន្ថែមថា ថ្វីត្បិតតែនារីអាចលេងបាល់ទាត់បានមែន ប៉ុន្តែតាមសភាពធម្មជាតិរបស់នារី ពួកគេនៅមានកម្លាំងកាយទន់ខ្សោយ និងមិនបានរឹងប៉ឹងដូចបុរសទេ។

ផាត សំភី

### ការបង្ហាញខ្លួន

នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៥ខាងមុខនេះ នឹងមានការប្រកួតបាល់ទាត់ពានរង្វាន់ឯកឧត្តម កែប ជុតិមា អភិបាលរាជធានីភ្នំពេញនៅវិទ្យាល័យបឹងកេងកងរវាងក្រុមយុវជននៅតាមវិទ្យាល័យនានា។ ពេលនោះ កីឡាការិនីបាល់ទាត់ក៏នឹងទៅចូលរួមបង្ហាញខ្លួនប្រកួតបើកឆាកផងដែរ។



# ទស្សនីយភាពសិល្បៈចម្លែក

**ពីមួយថ្ងៃទៅមួយថ្ងៃ សិល្បៈខ្មែរគ្រប់ទម្រង់ចេះតែមានវិវឌ្ឍន៍ពុំឈប់ឈរ និងមានការកែច្នៃខុសៗគ្នា។ នៅសម័យសកលភាវូបនីយកម្មនេះ វារឹតតែធ្វើឱ្យមានការចម្លែកទៅទៀតនោះគឺសិល្បៈបែបសម័យថ្មី ដែលក្នុងនោះគេយកអាវុធមកច្នៃធ្វើជារូបរាងផ្សេងៗ ដែលមានប្រយោជន៍។**



វាមិនមែនជាការងាយស្រួលទេក្នុងការយកគ្រឿងសព្វាវុធដ៏សាហាវមកច្នៃធ្វើជាវត្ថុសិល្បៈកំសាន្តភ្នែកដ៏អស្ចារ្យ។ រូបភាពជាច្រើន ដូចជារូបដរី សត្វស្លាប អណ្តើក កៅអី និងរូបផ្សេងៗទៀត ដែលធ្វើអំពីសំបកអាវុធគ្រប់ប្រភេទកំពុងឈរបង្ហួតរាងយ៉ាងសង្ហាក្នុងពិធីតាំងពិព័រណ៍មួយនៅវត្តភ្នំ ដែលចាប់ពីថ្ងៃទី១៩ សីហា ដល់ថ្ងៃទី៣០ កញ្ញា ឆ្នាំ២០០៥នេះ។ លោកអ៊ូ វណ្ណឌី អាយុ២៨ឆ្នាំ និស្សិតបញ្ចប់បរិញ្ញាប័ត្រផ្នែកចម្លាក់នៃមហាវិទ្យាល័យសិល្បៈសូនរូប និងជាម្ចាស់នៃរូបភាពមួយចំនួន បានមានប្រសាសន៍ថា សំបកកាំភ្លើងដែលអាចយកធ្វើជារូបភាពទាំងនេះបានមាន ដូចជា K59 M16 កាំភ្លើងយន្ត ព្រមទាំងអាវុធផ្សេងៗជាច្រើនប្រភេទទៀត។ លោកបានបន្តថា ការធ្វើរូបទាំងនេះអាចជួបគ្រោះថ្នាក់ដូចជាវាអាចផ្ទុះ ធ្វើឱ្យពិការដៃ ឬខ្ទាក់ភ្នែកជាដើម ។ តាមការពិត កាំភ្លើងមួយយើងមិនអាចធ្វើបានរូបមួយទេ គឺមានការរួមផ្សំគ្នាជាមួយនិងកាំភ្លើង ឬសំបកអាវុធផ្សេងៗទៀត ដូចជា នៅក្នុងរូបដរីមួយគឺយើងចំណាយកាំភ្លើងអស់ ៤០ដើម។ រីឯពេលវេលាធ្វើ គឺវាអាស្រ័យទៅលើរូបនោះធំ ឬតូច តួយ៉ាង រូបដរីមួយ ត្រូវចំណាយពេលជិតមួយខែ ប៉ុន្តែបើរូបនោះតូច ចំណាយពេលតែពីរ-បីថ្ងៃ ឬមួយសប្តាហ៍ គឺរួចរាល់ហើយ។ លោកវណ្ណឌីរៀបរាប់ទៀតថា ការតាំងពិព័រណ៍រូបភាពអាវុធនេះគឺចង់បង្ហាញអំពីសិល្បៈបែបថ្មីសម្រាប់ប្រជាជនខ្មែរ និងអំពីការរួមចំណែកប្រាប់ដល់មនុស្សទូទៅថា យើងលែងត្រូវការអាវុធទៀតហើយ។ យើងត្រូវការសន្តិភាព។ ការធ្វើបែបនេះផ្តល់អត្ថប្រយោជន៍ជាច្រើនដើម្បីអប់រំដល់យុវជនកុំឱ្យប្រើប្រាស់អាវុធដោយបង្ហាញថា ការប្រើអាវុធអាចធ្វើឱ្យគេមានទោស ដូចពាក្យស្លោកបរទេសមួយពោលថា: "ការស្រឡាញ់អាវុធប្រៀបដូចជាការរស់នៅជិតពស់វែក"។

មុំ គន្ធា

### បរិវត្តន៍អាវុធ

ខែតុលា ឆ្នាំ២០០៣ អង្គការសិល្បៈសន្តិភាពកម្ពុជាបានផ្តួចផ្តើមបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញគ្រឿងដែកដល់កូនជាងជាសិល្បករកម្ពុជាដោយប្រើអាវុធធ្វើជាវត្ថុធាតុដើមសម្រាប់ធ្វើការផលិតនូវរូបរាងផ្សេងៗ។



# បកប្រែភាសា

**តើជនជាតិបរទេសអាចទាក់ទងនឹងជនជាតិដើមដូចម្តេច? បើគេមិនចេះភាសានោះ។ អ្នកបកប្រែបានដើរតួនាទីមួយសំខាន់ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងនេះ។**



អ្នកបកប្រែភាសាធ្វើការមុខកុំព្យូទ័រដែលជាជំនួយក្នុងការងារ

Photo: R. Dina

### ការងារ

នេះគឺជាអាជីពមួយដែលទាមទារនូវចំណេះដឹងខ្ពង់ខ្ពស់ខាងភាសា។ ជាទូទៅសម្រាប់ការបកប្រែផ្ទាល់មាត់ អ្នកបកប្រែអាចប្រើប្រាស់កូនសៀវភៅកត់ត្រាតូចមួយដើម្បីជាជំនួយក្នុងការចងចាំរបស់គេ។ ចំណែកការបកប្រែអត្ថបទវិញ គេមិនតម្រូវឱ្យបកម្តងមួយពាក្យៗនោះទេ គឺគេតម្រូវឱ្យក្តោបយកខ្លឹមសារនៃអត្ថបទទាំងមូល។ ដើម្បីធ្វើដូច្នេះបាន ទាល់តែអ្នកបកប្រែត្រូវតែចេះសួរម្ចាស់ដើមនៃអត្ថបទដែលគេឱ្យបក ឬមួយក៏សួរជនបរទេស ឱ្យពន្យល់ត្រង់ឃ្លាណា ដែលពុំយល់។ កញ្ញាបេ ពុច អ្នកបកប្រែប្រចាំនៅកាសែតបារាំងកំបូដស៍និយាយថា: "ការបកប្រែជាការងារ ដែលទាមទារការទទួលខុសត្រូវខ្ពស់ ពីព្រោះយើងមិនអាចធ្វើការបកប្រែភាសាដោយខុសបានទេ ពោលគឺរក្សាខ្លឹមសារនៃភាសាទាំងពីរដែលយើងបកប្រែឱ្យបានដូចគ្នាជានិច្ច"។

### ប្រាក់ចំនូល

តាមធម្មតា អ្នកបកប្រែធ្វើការទទួលប្រាក់ខែដូចបុគ្គលិករដ្ឋ ក្រុមហ៊ុន ឬក៏អង្គការផ្សេងទៀតដែរ។ ប្រាក់ខែច្រើន ឬតិចវាអាស្រ័យលើការងារ និងបទពិសោធន៍របស់គេ។ ម្យ៉ាងវិញទៀត គេអាចបកប្រែយកកម្រៃក្រៅផងដែរ។ ជាទូទៅអ្នកបកប្រែអាជីព អាចទទួលបានប្រាក់កម្រៃ មិនក្រោម៨ដុល្លារឡើយសម្រាប់អត្ថបទមួយទំព័រ (ភាសាបារាំង)។

### ការសិក្សា

ដើម្បីធ្វើជាអ្នកបកប្រែ យើងត្រូវខំរៀនទាំងភាសាបរទេស និងភាសាជាតិឱ្យពូកែ។ កញ្ញាបេ ពុច ក្នុងបទពិសោធន៍បកប្រែរបស់ខ្លួនជាងបួនឆ្នាំផ្តល់យោបល់ថា: "ដើម្បីរៀនភាសាបរទេសបានពូកែ យើងត្រូវខិតខំអានសៀវភៅភាសា និងព្យាយាមធ្វើការទាក់ទងជាមួយជនបរទេសឱ្យបានច្រើន"។

ផាត សំភី

### គ្រឹះស្ថានសិក្សាភាសាបរទេស

វិទ្យាស្ថានភាសាបរទេស មានបង្រៀនទាំងភាសាអង់គ្លេស និងបារាំង។ ទូរស័ព្ទ: ០២៣ ៨៨៥ ៤១៩។ សាលាបង្រៀនភាសាអង់គ្លេស ACE ។ ទំនាក់ទំនងតាមទូរស័ព្ទ: ០២៣ ៧២៤ ២០៤។

# ដាំដើមឈើ

ពេលនេះ“អ្នកនាំសារ” សូមបង្ហាញអំពីវិធីដាំដើមឈើដ៏ងាយស្រួល។ ប្អូនៗ អាចធ្វើបានដើម្បីប្រើវាទុកតាំងលំអ ឬ ជូនជាកាដូសម្រាប់មិត្តភ័ក្តិក៏បានដែរ។





សម្ភារៈដែលត្រូវមានៈ កូនដបទឹកសុទ្ធជំរមួយ កែវជប់ខ្យល់មួយ សំលី ខ្សែប្រឆេះចង្កៀង គ្រាប់ពូជធញ្ញជាតិ មានដូចជា ស្រូវ សណ្តែក ល្ង ឪឡឹក -ល- ក្រដាសប្រវែង ២៤ សម x ៥ សម ហ្វឺត និងស្កុតបិទ។



១. កាត់ដបទឹកសុទ្ធជំររួច យកផ្នែកខាងក្បាលដប។



២. រុំសំឡីជុំវិញខ្សែប្រឆេះចង្កៀង រួចហើយដាក់វាចូលទៅក្នុងកំណាត់ដបទឹកសុទ្ធ។



៣. ដាក់កំណាត់ដបទឹកសុទ្ធទៅក្នុងកែវសម្រាប់ជប់ខ្យល់។ រាយគ្រាប់ពូជនៅលើសំឡីនោះ ហើយស្រោចទឹកវា។



៤. គូររូបគំនូរបែបកំប្លែងៗនៅលើ ក្រដាសមួយ។



៥. បិទក្រដាសនៅជុំវិញថូតូចនេះ។ ស្រោចទឹករាល់ថ្ងៃចាំមើល វានឹងដុះប្រហែលជាមួយអាទិត្យក្រោយមក។



# បរិយាកាសត្រូវបំពុល

នាពេលបច្ចុប្បន្ននេះ ផ្សែង និងឧស្ម័នផ្សេងៗ ដែលបានមកពីចំហេះ ដូចជា ការដុតសំរាម ផ្សែងឡាន ផ្សែងនៃរោងចក្រឧស្សាហកម្ម-ល- បានធ្វើឱ្យខ្យល់បរិយាកាសទទួលរងនូវការបំពុលជាខ្លាំង។ ផ្សែង និងឧស្ម័នទាំងនេះមានផ្ទុកទៅដោយឧស្ម័នកាបូនិច និងសមាសភាពគីមីផ្សេងៗ ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់ការដកដង្ហើមរបស់មនុស្ស និងសត្វ។ លើសពីនេះ ផលវិបាកមួយទៀតចំពោះការបំភាយផ្សែង និងឧស្ម័នទៅក្នុងខ្យល់បរិយាកាស គឺការកើនឡើងនូវកម្តៅនៅលើផែនដី ពីព្រោះផ្សែងទាំងនេះភាគច្រើន គឺជាឧស្ម័នកាបូនិចដែលជាអ្នករារាំងការផ្លាតត្រឡប់នៃកាំរស្មីព្រះអាទិត្យចេញពីផែនដីវិញ។ ហើយចំពោះការកើនឡើងនៃកម្តៅនៅលើផែនដីនេះវិញ គឺវាបានបង្កនូវគ្រោះថ្នាក់ជាច្រើនដល់មនុស្ស សត្វ និងរុក្ខជាតិ។ តួយ៉ាង វាធ្វើឱ្យអាកាសធាតុមានការផ្លាស់ប្តូរ។ ផែនទឹកកកនៅតំបន់ប៉ូលទាំងពីរនឹងរលាយ ដែលធ្វើឱ្យនីវ៉ូទឹកសមុទ្រកើនឡើងខ្ពស់ ដែលនេះនឹងធ្វើឱ្យអ្នករស់នៅលើតំបន់កោះ និងតាមតំបន់ទំនាបទទួលការគំរាមកំហែង ដោយទឹកជំនន់ជន់លិចនៅថ្ងៃណាមួយ ជាមិនខានដោយសារតែតំបន់ទាំងនេះស្ថិតនៅទាបជាងនីវ៉ូទឹកសមុទ្រ។

ម្យ៉ាងវិញទៀត ការកើនឡើងនៃសម្ពាធកម្តៅជះឥទ្ធិពលទៅលើប្រព័ន្ធអេកូឡូស៊ី (ប្រព័ន្ធបរិស្ថាន)ផងដែរ ដូចជា វាហុចផលប៉ះពាល់ទៅដល់រុក្ខជាតិ និងសត្វជាច្រើន ដែលអាចរស់នៅបានតែក្នុងតំបន់អាកាសធាតុត្រជាក់។ នៅពេលដែលកម្តៅផែនដីកើនឡើងសត្វទាំងនោះនឹងទៅជ្រកនៅកំពូលភ្នំខ្ពស់ៗ ដែលជាលំនៅចុងក្រោយហើយនឹងអាចផុតពូជផងដែរ។

ផាត សំភី



Photo: P. Samphy

ផ្សែងរថយន្តដែលបញ្ចេញមកគឺពោរពេញទៅដោយឧស្ម័នកាបូនិចដែលអាចបំពុលដល់បរិយាកាស

## យើងចូលចិត្ត!



នាពេលថ្មីៗ អង្គការស៊ីប៉ាបានចេញផ្សាយនូវសៀវភៅពីរក្បាល ដែលមានចំណងជើងថា “ដើមកំណើតសត្វកូនលោក” និង “ទំពាំងទូលដី”។ សៀវភៅទាំងពីរនេះគឺជារឿងនិទាន ដែលពោរពេញទៅដោយគំនិតអប់រំល្អៗ ដូចជាការបណ្តុះនូវសេចក្តីស្រលាញ់រវាងមនុស្ស និងធម្មជាតិ។ ហើយក្នុងមួយក្បាលៗ គេលក់ក្នុងតម្លៃ ១៩០០រៀល នៅតាមតូបសៀវភៅ ឬបណ្ណាគារនានា។

## យុវនារីក្នុងជំហានទី១នៃជីវិតអ្នកបួស



Photo: H. Sotheary

យុវនារីថតរូបអនុស្សាវរីយ៍ជាមួយលោកអភិបាល

កាលពីថ្ងៃទី០៨ កញ្ញា ឆ្នាំ២០០៥ នៅផ្ទះបងស្រីឧបការគុណ មានពិធីទទួលយុវនារីចំនួន ៣នាក់ ឱ្យចូលរួមជាសមាជិកនៃក្រុមអ្នកបួស។ ចូលរួមនៅក្នុងឱកាសនោះ មានលោកអភិបាលអេមីល ដេតម្ប ព្រមជាមួយនិងបងស្រី នៃក្រុមគ្រួសារឧបការគុណចំនួន ១២រូបទៀត។
យុវនារីទាំង ៣រូប គឺរួមមានកញ្ញាខាយ ធូយាម អាយុ ២៧ឆ្នាំ មកពីភូមិភាគកំពង់ចាម កញ្ញាឌិន ចន្ថា អាយុ ២២ឆ្នាំ មកពីព្រះសហគមន៍ស្វាយប៉ាក ភ្នំពេញ និងកញ្ញាពិសីមកពីក្រុងព្រះសីហនុ។ កញ្ញាឌិន ចន្ថា បាននិយាយថា: "ខ្ញុំពិតជារីករាយណាស់ ដែលព្រះជាម្ចាស់រើសខ្ញុំធ្វើជាអ្នកបម្រើព្រះអង្គ នៅក្នុងក្រុមបងស្រីឧបការគុណនេះ ប៉ុន្តែខ្ញុំពុំដឹងថា ថ្ងៃក្រោយនឹងជួបឧបសគ្គអ្វីទៀតទេ"។ បងស្រីអាញ៉េស ដែលជាប្រធានក្រុមគ្រួសារជូនជីឧបការគុណបញ្ជាក់ថា បងស្រីមានអំណរសប្បាយ ព្រោះតាំងពីសម័យសង្គ្រាមមក ទើបតែមាន ប្អូនៗ ៣ នាក់ទេ ដែលសម្រេចចិត្តចូលក្រុមគ្រួសារបងស្រីដើម្បីរិះគិតអំពីជីវិតអ្នកបួស។ ហ៊ួ សុខធារី

## ជួយប្អូនៗកុមារឱ្យបានចេះអានអក្សរ

ចាប់តាំងពីថ្ងៃ២៥ កក្កដា ដល់ថ្ងៃទី១៧ កញ្ញា នៅភូមិប៉ាង ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានកម្មវិធីមួយសម្រាប់ជួយដល់ក្មេងៗ ដែលមានអាយុពី៦ ដល់១៥ឆ្នាំ គឺការបង្រៀនពួកគេ។ កម្មវិធីនេះរៀបចំឡើងដោយព្រះសហគមន៍កំពង់ធំ ដែលមានបងស្រីសុដាធិបគឺជាអ្នកទទួលខុសត្រូវ។ គោលបំណងក្នុងការរៀបចំកម្មវិធីនេះឡើង គឺដើម្បីជួយបង្រៀនប្អូនៗនៅក្នុងភូមិដាច់ស្រយាលឱ្យចេះអានអក្សរ គិតលេខ និងរៀបចំអនាម័យ។ យុវជនប្រមាណជា ៥នាក់ មកពីមណ្ឌលសិស្សកំពង់ធំ ចំណាយពេលវេលារបស់ពួកគេដើម្បីចែករំលែកនូវចំណេះដឹង ដែលពួកគេមាន ដល់ក្មេងៗដែលរស់នៅតាមជនបទដាច់ស្រយាលក្រីក្រទាំងនេះ ក្នុងឱកាសដែលពួកគេឈប់សម្រាកពីការសិក្សា។ បងស្រី កល្យាណ

## ខ្ញុំសូមឃ្លាតកម្ពុជាទាំងក្តីអាល័យ



Photo: L. Sovanna

កាលថ្ងៃទី២ ខែកញ្ញា ឆ្នាំ ២០០៥ កន្លងទៅ លោកឪពុកតូ តែតនៃព្រះសហគមន៍បាត់ដំបង បានចាកចេញពីកម្ពុជា ទៅទទួលការរៀនសូត្របន្ថែម ក្នុងដំណាក់កាល ទី៣ នៃក្រុមអ្នកបួសនៅក្នុងក្រុមគ្រួសារសហជីវិន ព្រះយេស៊ូរយៈពេល១ឆ្នាំ។ រយៈពេល ៣ឆ្នាំ ចំពោះការបំពេញបេសកកម្មនៅព្រះសហគមន៍ បាត់ដំបង លោកឪពុកបានបញ្ជាក់ថា: "ខ្ញុំមានអំណរសប្បាយណាស់ ដោយបានបម្រើ និងកសាងព្រះសហគមន៍ រួមជាមួយបងប្អូនខ្មែរ"។ ហើយថ្ងៃអនាគត លោកពុំដឹងថា នឹងបានត្រឡប់មកវិញឬអត់នោះទេ។ វាគឺអាស្រ័យលើការចាត់ចែងពីលោកប្រធានក្រុមសហជីវិនព្រះយេស៊ូ។ លី សុវណ្ណា

## ព្រឹត្តិការណ៍នឹងមាន!

- ថ្ងៃទី២២ កញ្ញា: មណ្ឌលនិស្សិតនៃព្រះសហគមន៍កាតូលិកទទួលស្វាគមន៍និស្សិតថ្មីឱ្យចូលមកស្នាក់នៅចំនួន ១៦នាក់។
- ថ្ងៃទី០១ តុលា: មានប្រជុំរាល់ទីប្រឹក្សាអន្តរនិកាយដោយមាន ២០ព្រះវិហារ ចូលរួមជាមួយនិកាយកាតូលិក (កំពង់ចាម)។
- ថ្ងៃទី០៣ តុលា: មានរៀបចំអធិដ្ឋានដល់អ្នកស្លាប់ ព្រមជាមួយនិងការចែកអំណោយដល់ប្រជាជនក្រីក្រចំនួន ១០០គ្រួសារនៅព្រះវិហារផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី០៥ តុលា: មានពិធីបើកបវេសនកាលនៃឆ្នាំសិក្សាថ្មីនៅវិទ្យាល័យសន្តហ្វ្រង់ស័រនៅព្រះសហគមន៍ចំការទៀង ខេត្តតាកែវ។
- ថ្ងៃទី១០ តុលា: ពិធីបើកបវេសនកាលរបស់សាលាបច្ចេកទេសដុនបូស្កូ ទួលគោកទឹកថ្លា និងភ្នំពេញថ្មី រាជធានីភ្នំពេញ។
- ថ្ងៃទី២០ តុលា: ដំណើរទស្សនកិច្ចនៅប្រទេសជប៉ុនរយៈពេល ១០ថ្ងៃ របស់សិស្សានុសិស្ស ១០នាក់ រួមជាមួយនិងថ្នាក់ដឹកនាំ នៃវិទ្យាល័យសន្តហ្វ្រង់ស័រក្រោមការអញ្ជើញរបស់វិទ្យាល័យគូម៉ាម៉ូតុ ដែលជាបងប្អូនធម៌នឹងវិទ្យាល័យសន្តហ្វ្រង់ស័រ។
- ថ្ងៃទី២៦ តុលា: មានរៀបចំការប្រជុំរបស់ទីប្រឹក្សាលោកអភិបាល ដូនជី និងលោកអភិបាល រិះគិតអំពីសកម្មភាពនានារបស់ព្រះសហគមន៍នៅភូមិភាគកំពង់ចាម។

**កម្មវិធីវិទ្យុ: យុវវ័យសម័យទំនើប!**
មានចាក់ផ្សាយនៅវិទ្យុគ្រួសារថ្មី ប៉ុស្តិ៍ FM 99.5 MHz វេលាម៉ោង១ និង៣០នាទីពេលថ្ងៃហើយផ្សាយឡើងវិញនៅម៉ោង៨ និង៣០នាទីពេលយប់នៅថ្ងៃសៅរ៍រៀងរាល់សប្តាហ៍។ ទូរស័ព្ទ: ០១៦៣២៦៧៣២។ សូមកុំភ្លេច!

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ ហៃរណាន់ ពីនីឡា